# សង្ខេបកថា

គម្រោងទីក្រុងឡូវែលឆ្ពោះទៅមុខ (Lowell Forward) ជាផែនការស៊ីជម្រៅសម្រាប់អនាគតរបស់ទីក្រុងយើង។ គម្រោងនេះមានបញ្ចូលចក្ខុវិស័យរយៈពេលម្ភៃឆ្នាំ និងផែនទីបង្ហាញផ្លូវសម្រាប់គាំពារការរីកចំរើន និងវិនិយោគនៅតំបន់ទីប្រជុំជនក្រុង ភូមិឋាន សហគមន៍ ទីធ្លាសាធារណៈ និងកន្លែងធម្មជាតិ និងបណ្តាញហេដ្ឋារចនាសម្ព័ន្ធរបស់យើង។ ផែនការនេះជាកិច្ចការសមូហភាព ដែលកើតចេញពីចក្ខុវិស័យ និងការប្តេជ្ញារបស់មេដឹកនាំ និងពលរដ្ឋសហគមន៍របស់យើង និងឆ្លុះបញ្ចាំងនូវការខិតខំយ៉ាងខ្លាំងក្លាពីមនុស្សច្រើនរាប់មិនអស់ ដែលអ្នកទាំងអស់គ្នាសុទ្ធតែតាំងចិត្តដើម្បីធ្វើឲ្យទីក្រុងរបស់ពួកគាត់ចម្រុងចម្រើនទៅអនាគត។

## ការចូលរួមរបស់សហគមន៍ *ទំព័រទី ៤១*

ក្រុមនៃគម្រោងឡូវែលឆ្ពោះទៅមុខ ជួបពិគ្រោះជាមួយសហគមន៍ រួមទាំងកិច្ចសន្ទនាគ្នាដែលមានការចូលរួមពីគ្រប់ស្រទាប់វណ្ណៈ ដើម្បីកំណត់ចំណុចអាទិភាពរួមរបស់សហគមន៍ និងបង្កើតចក្ខុវិស័យសម្រាប់អនាគតនៃទីក្រុងឡូវែល។ ការចូលរួមរបស់សហគមន៍នេះ ត្រូវបានគិតគូរឲ្យមាននៅរាល់ជំហាននីមួយៗនៃដំណើរការគម្រោងនេះ ដោយយើងវិនិយោគយ៉ាងច្រើនទៅលើពេលវេលា និងធនធាន រួមទាំងមុខតំណែងពេញម៉ោងនៃអ្នករៀបចំសហគមន៍ និងមានក្រុមគោលដៅពិភាក្សាជាបន្តបន្ទាប់ ដែលដឹកនាំដោយសាលាក្រុង សិក្ខាសាលាសាធារណៈទូទាំងទីក្រុងចំនួនបីលើក ការស្ទង់មតិទូទាំងក្រុងចំនួនពីរ និងការផ្សព្វផ្សាយតាមបណ្តាញផ្សព្វផ្សាយសង្គម។

គោលដៅសម្រាប់ជំពូកនេះ៖ **ពន្យល់ពលរដ្ឋសហគមន៍គ្រប់រូប**

## ចក្ខុវិស័យរបស់យើង *ទំព័រទី ៤២*

គម្រោងឆ្ពោះទៅមុខនេះ គឺយើងចង់ឃើញឡូវែលជាទីក្រុងមួយដែល៖



ផ្សារភ្ជាប់ជាមួយសហគមន៍យើងខាងផ្នែកលំនៅឋាន និងធនធានដែលចាំបាច់ ដើម្បីរស់នៅក្នុងជីវិតមួយពេញបរិបូណ៌



ស្វាគមន៍ ប្រារព្ធ លើកតម្កើងភាពចម្រុះ និងបេតិកភណ្ឌពិសេសរបស់យើង



ដឹកជញ្ជូនយើងដោយងាយស្រួលទៅកាន់ទីដែលយើងត្រូវការទៅ មិនថាតាមរថយន្ត ប្រព័ន្ធដឹកជញ្ជូនសាធារណៈ ថ្មើរជើង ឬជិះកង់



យកចិត្តទុកដាក់ថែរក្សាទីធ្លាសាធារណៈ ធនធានធម្មជាតិរបស់យើង និងយកចិត្តទុកដាក់ដល់គ្នាទៅវិញទៅមក



បង្កើតឱកាសអប់រំ និងសេដ្ឋកិច្ចសម្រាប់រីកចំរើនគ្រប់គ្នា



ត្រៀមរៀបចំខ្លួន និងឆ្លើយតបទៅនឹងផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ

## គោលជំហរជាមគ្គុទ្ទេសក៍របស់យើង *ទំព័រទី ៤២*

និរន្តរភាព និងភាពធន់

ការថែរក្សាទុកជាមុន

អភិបាលកិច្ចដោយការទទួលខុសត្រូវ និងការគ្រប់គ្រងសហគមន៍ដោយយកចិត្តទុកដាក់

ការបង្កើតថ្មី និងភាពច្នៃប្រឌិត

# គោលដៅជាអាទិភាព និងចំណាត់ការ *ទំព័រទី ៨១*

គោលដៅសម្រាប់ជំពូកនេះ៖ **សម្រាប់អ្នកចាត់ចំណាត់ការ**

## ការប្រើប្រាស់ដីធ្លី និងទម្រង់ទីក្រុង

១) ការរីកលូតលាស់ទីប្រជុំជនក្រុង
២) ការរីកលូតលាស់មជ្ឈមណ្ឌលសកម្មភាពតាមភូមិ និងភាពជាដៃគូជាមួយមេដឹកនាំតាមស្ថាប័ន
៣) អភិវឌ្ឍឡើងវិញតំបន់ដែលមិនបានប្រើប្រាស់ពេញលេញ ឬតំបន់ពាណិជ្ជកម្មមមាញឹក

## លំនៅឋាន

១) ផែនការសម្រាប់លូតលាស់បែបសមធម៌ និងបានផលគ្រប់គ្នា
២) បង្កើតលំនៅឋានសម្រាប់គ្រប់គ្នា
៣) បង្កើនគុណភាពលំនៅឋាន
៤) លុបបំបាត់ភាពអនាថា និងកាត់បន្ថយអសន្តិសុខលំនៅឋាន
៥) ផ្តល់ជម្រើសលំនៅឋានសម្រាប់គ្រួសារ ដែលមានប្រាក់ចំណូលទាប និងទាបខ្លាំង
៦) ពង្រីក និងបង្កើតឱកាសថ្មីៗសម្រាប់កម្មសិទ្ធិផ្ទះតម្លៃសមរម្យ
៧) ធានាឲ្យមានគោលនយោបាយ និងការអនុវត្តផ្នែកលំនៅឋានដោយយុត្តិធម៌

## ការធ្វើដំណើរ

១) បណ្តាញផ្សារភ្ជាប់ការធ្វើដំណើរដោយសុវត្ថិភាព និងមានសមធម៌ ដែលសម្រួលដល់មនុស្សគ្រប់គ្នា រួមទាំងអ្នកថ្មើរជើង អ្នកជិះកង់ អ្នកបើករថយន្ត និងជិះយានផ្សេងទៀត
២) ផ្តល់មធ្យោបាយងាយស្រួល និងបង្ហាញផ្លូវសម្រាប់ជម្រើសដឹកជញ្ជូន
៣) មធ្យោបាយធ្វើដំណើរមានគុណភាពខ្ពស់ និងគួរឲ្យទុកចិត្ត និងលើកទឹកចិត្តឲ្យប្រើមធ្យោបាយដឹកជញ្ជូន

## ការអភិវឌ្ឍសេដ្ឋកិច្ច

១) កែលម្អតំបន់ទីប្រជុំជន
២) លើកកម្ពស់ គាំពារ និងបង្កើនអាជីវកម្មមូលដ្ឋានក្នុងក្រុងឡូវែល
៣) ពង្រីកឱកាសពាណិជ្ជកម្ម និងឧស្សាហកម្ម និងបង្កើនឱកាសការងារសម្រាប់ពលរដ្ឋឡូវែល

## ថាមពល អាកាសធាតុ និងបរិស្ថាន

១) សម្រេចកាត់បន្ថយកាបូនឲ្យទាបបំផុតត្រឹមឆ្នាំ ២០៥០
២) កសាងភាពធន់នឹងវិបត្តិ
៣) លើកកម្ពស់សេដ្ឋកិច្ចថាមពលស្អាត
៤) សមធម៌ថាមពល៖ ធានាសម្រេចឲ្យបានគោលដៅកាត់បន្ថយកាបូន ដោយមិនឲ្យកើនភាពមិនសមមាត្រលើបន្ទុកថាមពលសម្រាប់ពលរដ្ឋដែលងាយរងគ្រោះភាគច្រើនរបស់យើង

## ឧទ្យាន ទីធ្លាសាធារណៈ និងផ្លូវហាត់ប្រាណ

១) ពង្រឹងភាពធន់នឹងវិបត្តិសង្គម សមធម៌ ការទទួលបានសេវា និងការថែទាំឧទ្យាន ទីធ្លាសាធារណៈ និងផ្លូវហាត់ប្រាណ
២) ពង្រឹងភាពធន់នឹងអាកាសធាតុ និងនិរន្តរភាពក្នុងឧទ្យាន ទីធ្លាសាធារណៈ និងផ្លូវហាត់ប្រាណ

## សិល្បៈ និងវប្បធម៌

១) លើកតម្លៃសិល្បៈ និងគាំពារគំនិតច្នៃប្រឌិតបង្កើតទីធ្លាសាធារណៈនៅឡូវែល
២) គាំពារជីវិតសេដ្ឋកិច្ចឡូវែល តាមរយៈសិល្បៈ វប្បធម៌ និងការច្នៃប្រឌិត

## ក្របខណ្ឌអនុវត្ត

*ទំព័រទី ១៦៥*

ក្របខណ្ឌនៃការអនុវត្តគម្រោងឡូវែលឆ្ពោះទៅមុខនេះ កំណត់ក្របខណ្ឌសម្រាប់គោលដៅ និងចំណាត់ការដើម្បីជួយដល់**អ្នកចាត់ចំណាត់ការ** ដូចជានាយកដ្ឋាន អង្គការមូលដ្ឋាន មេដឹកនាំស្ថាប័ន និងសហគមន៍ ក្នុងការកំណត់ចំណុចអាទិភាពភារកិច្ច និងជំហានបន្ទាប់។

សូមអានទំព័របន្ទាប់សម្រាប់
យុទ្ធសាស្ត្រសម្រាប់ការអភិវឌ្ឍ និងផ្លាស់ប្តូរ →

# យុទ្ធសាស្ត្រសម្រាប់អភិវឌ្ឍន៍ និងការផ្លាស់ប្តូរ

ទំព័រទី ៥៥

ស្របពេលដែលទីក្រុងឡូវែលអភិវឌ្ឍ ទីក្រុងនេះនឹងជួបឱកាសថ្មីៗ និងបញ្ហាប្រឈមនានា ដែលកំណត់ការលូតលាស់ និងការប្រែធាតុរបស់ខ្លួន។ ផែនការនេះផ្តល់ជាឱកាសសំខាន់មួយ សម្រាប់សាលាក្រុង និងសហគមន៍ ក្នុងការកំណត់ចំណុចកែលម្អជាក់លាក់ ដែលយើងផ្តល់តម្លៃ សម្រាប់ភូមិឋានរបស់យើង និងដើម្បីកំណត់នូវទំហំនៃការផ្លាស់ប្តូរដែលយើងអាចសម្របខ្លួនទទួលយកបាន។ ជំពូកទី ៣ មានរៀបរាប់អំពីយុទ្ធសាស្ត្រ ដែលមានគោលដៅណែនាំ និងកំណត់ការលូតលាស់ និងអភិវឌ្ឍន៍ដោយចីរភាព និងសមធម៌ក្នុងទីក្រុងឡូវែល។ យុទ្ធសាស្ត្រទាំងនេះត្រូវបានបង្កើតឡើង ក្នុងកិច្ចសហប្រតិបត្តិការគ្នាជាមួយសហគមន៍ និងបានទទួលព័ត៌មានតាមរយៈកិច្ចសន្ទនាគ្នាជាច្រើន និងការផ្តល់យោបល់ផ្សេងៗ ដែលទទួលបានក្នុងដំណើរការចូលរួមបង្កើតគម្រោងទីក្រុងឡូវែលឆ្ពោះទៅមុខនេះ។

អតិថិជនគោលដៅសម្រាប់ជំពូកនេះ៖ **អ្នកចាត់ចំណាត់ការ**

១) អភិវឌ្ឍ និងធ្វើឲ្យតំបន់ទីប្រជុំជនក្រុងយើងរស់រវើក

២) កសាងលើគ្រឹះនៃកម្លាំងពិសេសរបស់យើង៖ មជ្ឈមណ្ឌលភូមិឋាន និងមេដឹកនាំស្ថាប័ន

៣) បង្កើតឱកាសក្នុងតំបន់ឧស្សាហកម្មជាយុទ្ធសាស្ត្រ



## ១) អភិវឌ្ឍ និងធ្វើឲ្យទីប្រជុំជនក្រុងយើងរស់រវើក

### ១.១៖ បង្កើនរបាយប្រជាពលរដ្ឋ ធ្វើឲ្យទីប្រជុំជនក្រុងមានភាពរស់រវើក និងតភ្ជាប់គ្នា




គាំពារឲ្យមានសង្កាត់ទីប្រជុំជនក្រុងមានភាពរស់រវើក បើក ២៤ ម៉ោងលើ ២៤ម៉ោង និង ៧ ថ្ងៃ ក្នុងមួយសប្ដាហ៍ ដែលទាក់ទាញភ្ញៀវចម្រុះ និងនាំអត្ថប្រយោជន៍ជាច្រើនដល់សហគមន៍កាន់តែទូលំទូលាយ

### ១.២៖ ធ្វើឲ្យតំបន់មាត់ទន្លេ និងប្រឡាយមានភាពរស់រវើក



ប្រើប្រឡាយរបស់យើងឲ្យអស់ពីលទ្ធភាព ដើម្បីក្លាយជាប្រព័ន្ធភ្ជាប់ទំនាក់ទំនង បទពិសោធន៍ និងមុខមាត់ក្រុងឡូវែល

### ១.៣៖ បំពេញចន្លោះនៅតំបន់ស្នូលកណ្ដាល




បង្កើនរបាយប្រជាពលរដ្ឋនៅក្នុង និងនៅជុំវិញទីប្រជុំជនក្រុង ដោយរៀបចំផែនការប្រើប្រាស់តំបន់ដែលមានចាក់ដីពេញរួច សម្រាប់ភូមិឋានតូចៗ ដែលអាចប្រើប្រាស់បានច្រើនយ៉ាង និងអាចដើរទៅដល់។

## ២) ពង្រឹងគ្រឹះខ្លាំងពិសេសរបស់ទីក្រុងឡូវែល

### ២.១៖ ពង្រឹងតំបន់ភូមិឋាន




លើកកម្ពស់ការអភិវឌ្ឍដែលអភិរក្សមូលដ្ឋាន ដែលពង្រឹងគុណតម្លៃភូមិឋាន កែលម្អការផ្សារភ្ជាប់ទំនាក់ទំនង និងសាទរចំពោះអត្តសញ្ញាណពិសេសនៃភូមិនីមួយៗ

### ២.២៖ ប្រើប្រាស់ហាងទំនិញធំៗឲ្យអស់លទ្ធភាព




បង្កើតយុទ្ធសាស្ត្រជាដៃគូគ្នាជាមួយអាជីវកម្មធំៗ ដើម្បីគាំពារអាជីវកម្មខ្នាតតូច ផ្ដល់ការងារធ្វើ និងជំរុញកំណើនសេដ្ឋកិច្ចទីក្រុង និងបង្កើតបរិយាកាសអំណោយផល

## ៣) បង្កើតឱកាសក្នុងតំបន់ឧស្សាហកម្មជាយុទ្ធសាស្ត្រ




មានឱកាសជាច្រើន ដើម្បីអភិវឌ្ឍទីតាំងឧស្សាហកម្មចាស់ៗ នៅទូទាំងទីក្រុងឡូវែល សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចថ្មី និងគម្រោងបង្កើតការងារ។ ទាំងនេះរួមមានឧទ្យានឧស្សាហកម្មទីក្រុង Ayer ឬច្រកផ្លូវ Tanner និងតំបន់នៅបណ្ដោយផ្លូវ Western Ave និងប្រឡាយ Pawtucket នៅតំបន់ Acre។

# ការចូលរួមរបស់សហគមន៍ ទំព័រទី ៤១

## ការចូលរួមរបស់សហគមន៍មានបីដំណាក់កាលដូចបង្ហាញជូនខាងក្រោម៖




## ដំណាក់កាលទី ១៖ ការសិក្សា និងរៀបចក្ខុវិស័យ

### សិក្ខាសាលាសាធារណៈលើកទី ១៖



មានអ្នកចូលរួមជាង **១០០** នាក់ និងមានមតិជាលាយលក្ខណ៍អក្សរ និងសរសេរក្រដាស **៣០០** មតិ

### ចក្ខុវិស័យទូទាំងក្រុង និងការស្ទង់មតិអំពីគោលដៅ ១៖



មានអ្នកឆ្លើយតប ជាង **៧០០**ចម្លើយ

### អ្នករៀបចំសហគមន៍៖



កិច្ចសន្ទនា **២១**
ប័ណ្ណមតិ **៤០**

### ក្រុមគោលដៅរបស់ក្រុង៖



**១០** ប្រធានបទជាក់លាក់សម្រាប់ក្រុមគោលដៅ

### កិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍៖



ប្រជុំ **២** លើក

## ដំណាក់កាលទី ២៖ ធ្វើតេស្តចក្ខុវិស័យអនាគត

**សិក្ខាសាលាសាធារណៈទី ២៖**

មានអ្នកចូលរួមជាង **៤០** នាក់ និង មានមតិជាលាយលក្ខណ៍អក្សរ និង សរសេរបិត **១៧៨** មតិ

**ចក្ខុវិស័យទូទាំងក្រុង និងការស្ទង់មតិអំពីគោលដៅទី ២៖**

មានអ្នកឆ្លើយតប ជាង **៣៦៦** នាក់

**អ្នករៀបចំសហគមន៍៖**

មានកិច្ចសន្ទនាចំនួន **៨** ឬក្រុមគោលដៅ

**ក្រុមគោលដៅដឹកនាំដោយក្រុង៖**

ក្រុមគោលដៅផ្តោតលើ ប្រធានបទជាក់លាក់ **៧** និង ក្រុមគោលដៅភូមិ ជាក់លាក់ **៨**

**កិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍៖** ប្រជុំ **២** លើក

## ដំណាក់កាលទី ៣៖ បង្កើតផែនការ

**សិក្ខាសាលាសាធារណៈទី ៣៖**

ភាពជាដៃគូជាមួយ CHOP Dinner

អ្នកចូលរួមជាង **១៤០** នាក់ និង មានសរសេរបិតជាង **៧០០** ប្រតិកម្មលើក្តារខៀន។

**អ្នករៀបចំសហគមន៍៖**

សន្ទនា **១០** លើកផ្តោតលើប្រធានបទគោលដៅជាក់លាក់ និងចំណាត់ការរួមមាន៖

- អង្គការមូលនិធិដៃគូលំនៅឋាន សហគមន៍ Merrimack Valley
- ម្ចាស់អាជីវកម្មខ្នាតតូច
- គម្រោង Project Learn
- អង្គការ Coalition for a Better Acre Alliance
- អង្គការ Lowell Litter Krewe
- អង្គការ Greater Lowell
- សាលាសាធារណៈក្រុងឡូវែល
- អង្គការ Mill City Grows
- អង្គការសុខភាពមហាតំបន់ឡូវែល
- អង្គការ Mary Wambui

**កិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍៖** ប្រជុំ **២** លើក